ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

~~~***~~~

សាលាដំបូងខេត្តកណ្តាល

សាលក្រមព្រហ្មទណ្ឌលេខៈ ២៣៦(ឆ)

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ៖

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកណ្តាល

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

## មេធាវី

លោក [redacted] និងឈ្មោះ [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted] វិបុល

លោក [redacted] ជាមេធាវីការពារក្តីអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធឿន

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ **២៧៧ អក** ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] **វិបុល** ភេទប្រុស អាយុ ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ បើកបរឡានដឹកស្រូវ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ស្រេង (រ) ម្តាយឈ្មោះ [redacted] ស៊ឹម (រ) ប្រពន្ធឈ្មោះ [redacted] ស្រីរ័ត្ន មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (ក្នុងឃុំ ២១/០២/២០២០ ក្រៅឃុំ០៧/០៤/២០២០)

ពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិពាមរាំងលើ ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] កសី ភេទប្រុស មុខរបរ បើកឡានដឹកដី ទីលំនៅសព្វថ្ងៃនៅភូមិព្រែកតូច ឃុំព្រែកទន្លាប់ ស្រុកលើកដែក ខេត្តកណ្តាល។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ុនធឿន** ភេទស្រី អាយុ ៣៩ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិព្រែកតូច ឃុំព្រែកទន្លាប់ ស្រុកលើកដែក ខេត្តកណ្តាល។

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង២១ និង ៣០នាទី មានជនជាប់ចោទឈ្មោះ [redacted] វិបុល បានបើកឡានដឹកស្រូវទៅលក់នៅម៉ុកោះរកា ដល់សាលាឃុំពាមរាំងស្ថិតនៅភូមិពាមរាំងលើ ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្តាល ក៏បានប៉ះគ្នាជាមួយឡានមួយគ្រឿងទៀត ហើយជនជាប់ចោទបានចុចស៊ីផ្លេអោ
~~~

យឈប់ រួចដើរទៅបើកទ្វារឡាន ចាប់ទាញព្រូឡានឈ្មោះ [redacted] ភស័ ចុះមកដី បណ្ដាលអោយដួលបោកផ្ទប់ទៅនឹងផ្លូវកៅស៊ូរងបណ្ដាលឲ្យរបួស ។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខៈ ១០៦៣ ដក.សព/២០ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-ដីកាដំណោះស្រាយលេខៈ ១១២៩ ដកជស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ។

-ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១២៤៣ ដកចត/២០ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។

## នាពេលសវនាការ

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីការពារក្ដីឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីការពារក្ដីឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

## សំអាងហេតុ

១-កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្ថិតនៅភូមិពាមរាំងលើ ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្ដាល ពិតជាកើតមាននូវអំពើ ហិង្សាដោយចេតនា ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទ ស្រេង វិបុល បានធ្វើសកម្មភាពទាញចាប់ជនរងគ្រោះពីក្នុងឡាន បណ្ដាលឲ្យរងរបួស ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិបុល បានឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ពេលខ្លួនបើកឡានដឹកស្រូវចូលទៅលក់នៅកោះរកា មុំសាលាឃុំពាមរាំង ស្រាប់តែមានឡានដឹកដីមួយគ្រឿងបើកគៀរឡានខ្លួន បន្ទាប់មកខ្លួនបានហៅអ្នកបើកឡាននោះអោយចុះមកនិយាយគ្នា ដោយបើកទ្វារទាញឈ្មោះ [redacted] ចុះ តែឈ្មោះនេះបានដួលពីលើឡានព្រោះមានសភាពស្រវឹង ។ ពេលនោះខ្លួនបានដើរទៅខាងតៃកុងឡានម្ដង ដើម្បីនិយាយគ្នា ខណៈនោះតៃកុងឡានបានចុះមកសំពះសុំទោសដោយស្ថិតក្នុងសភាពស្រវឹង ហើយខ្លួនក៏ឲ្យអោយពួកគេត្រឡប់ទៅវិញ ។ ឃើញថា ចម្លើយនេះអាចឲ្យតុលាការជឿបាន ព្រោះថា ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រីនគបាលយុត្តិធម៌ ។

៣-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ភស័ បានបញ្ជាក់ថាៈ នៅថ្ងៃកើតហេតុ ខ្លួនបានជិះឡានដឹកដីម៉ាកហ៊ីយ៉ាន់ដាយ ចង្កូតស្ដាំជាមួយឈ្មោះ រុន ពេលបើកបានប្រហែល២ គីឡូម៉ែត្រ ឈ្មោះ រុន បានបន្ថែមល្បឿនវ៉ាឡានដឹកស្រូវ ពេលនោះឡានដឹកស្រូវស៊ីផ្លេ រួចឈ្មោះ រុន បានឈប់និងចុះពីលើឡាន ស្រាប់តែឈ្មោះ [redacted] វិបុល បានមកដល់មិននិយាយអ្វីនោះទេ និងបានវាយខ្លួនចំមួយដៃពីក្រោយដួលបោកក្បាលទៅ

Scanned with CamScanner

នឹងផ្លូវ ពេលនោះខ្លួនបានបាត់ស្មារតីវង្វេងលែងដឹងអី ។ ឃើញថា ចម្លើយនេះគ្រាន់តែជាអះអាងប៉ុណ្ណោះ ពុំមានសាក្សីមកបញ្ជាក់គ្រប់គ្រាន់ដែលធ្វើឲ្យតុលាការជឿបានឡើយ ព្រោះថា ចម្លើយនេះមានភាពផ្ទុយគ្នាទៅនឹងចម្លើយសាក្សីឈ្មោះ [redacted] ភារុន និងឈ្មោះ [redacted] ស៊ុន ត្រង់ថាបានឃើញជនជាប់ចោទទាញជនរងគ្រោះចុះពីលើឡាន ហើយមិនមានឃើញជនរងគ្រោះរបួសធ្ងន់នោះឡើយ ។

៤-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ុនធឿន** បានឆ្លើយថា៖ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង៧ព្រឹក មានម្ចាស់ផ្ទះឈ្មោះ ឡា បានទូរសព្ទមកប្រាប់ខ្លួនថា ប្អូនខ្លួនឈឺ។ ពេលខ្លួនទៅដល់ឃើញប្អូនជាំភ្នែក និងប៉ោងក្បាលខាងក្រោយ តែមិនមានឈាមនោះទេ ។

៥-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **ភារុន** បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុខ្លួននិងឈ្មោះ [redacted] ភ័ស បានចេញពីកន្លែងផឹកស៊ី ដោយខ្លួនជាអ្នកបើកក្នុងស្ថានភាពស្រវឹង ពេលដល់ចំនុចកើតហេតុខ្លួនបានបើក ជែងឡានមួយគ្រឿង បណ្តាលឲ្យឡាននោះបែកស្កុបនិងកាងឡាន ពេលនោះម្ចាស់ឡាននោះក៏បានទាញដៃឈ្មោះ ភ័ស ចុះពីឡានបណ្តាលឲ្យដួលទៅលើថ្នល់ ។

៦-តាមចម្លើយសាក្សីឈ្មោះ [redacted] **ស៊ុន** បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានឃើញឡានធំពីរឈប់នៅមុខផ្ទះខ្លួន និងបានឃើញមនុស្សប្រុសស្រីដែលបើកឡានពណ៌ស កំពុងជជែកគ្នាជាមួយមនុស្សប្រុសពីរនាក់ ហើយមនុស្សស្រីនោះបានឃាត់ឡានឲ្យឈប់ដើម្បីឲ្យឈប់និយាយគ្នាព្រោះឃើញមានភាពស្រវឹងខ្លាំង ។ ខ្លួនមិនបានឃើញជនរងគ្រោះមានរបួសនោះទេ ។

៧-ទាំងចម្លើយរបស់ជនជាប់ចោទ , ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយជនរងគ្រោះ ចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នាដែលកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន ។

៨-អំពើរបស់ជនជាប់ចោទបានស្តែងឡើង មានចេតនាធ្វើឲ្យជនរងគ្រោះរងរបួស ដោយបានទាញជនរងគ្រោះធ្លាក់ពីលើឡាន ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ។

៩-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទក្នុងកំរិតដាក់ពន្ធនាគារ ១(មួយ)ឆ្នាំ និងឲ្យអនុវត្តទោសព្យួរធម្មតាមួយផ្នែក ដោយពិចារណាទៅលើលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោម:

+អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ រូបរាងកាយរបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ។

+សកម្មភាពល្មើសពុំបង្កឲ្យមានព្យសនៈកម្មធ្ងន់ធ្ងរឡើយ ។

+ចៅក្រមស៊ើបសួរបានសម្រេចឲ្យជនជាប់ចោទបាននៅក្រៅឃុំបណ្តោះអាសន្ន។ មូលហេតុទាំងនេះហើយនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៨.០០០$(ប្រាំបីពាន់)ដុល្លារអាមេរិក ឃើញថាបណ្តឹងនេះធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា១៣ , មាត្រា១៤ , មាត្រា១៥ , មាត្រា២១ និងមាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអាចពិនិត្យនិងសម្រេចបានតាមមាត្រា២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមការពិនិត្យឃើញថា ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើនដែលគប្បីតុលាការបន្ធូបន្ថយឲ្យបានសមស្របទៅនឹងទំហំព្យសនៈកម្មជាក់ស្តែង។

Scanned with CamScanner

១១-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ឃើញថា ពិតជាមាននូវអង្គហេតុនៃអំពើហិង្សាដោយចេតនាប្រាកដមែន ។ ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទពីបទ ហិង្សាដោយចេតនា ។ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ លេខ: ១០៦៣ ដក.សព/២០ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ស្នើសុំឲ្យតុលាការសម្រេចតាមច្បាប់ ។ តុលាការយល់ស្របនឹងសេចក្តីសន្និដ្ឋាននេះ ។

១២-មេធាវីការពារក្តីឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ឃើញថា ពិតជាមានអំពើគ្រោះថ្នាក់ចរាចរណ៍ប្រាកដមែន ហើយអំពើនេះមិនមែនជាអំពើហិង្សាដោយចេតនាទេ ។ តាមចម្លើយរបស់ជនរងគ្រោះ គឺផ្ទុយទៅនឹងចម្លើយសាក្សី , តាមរូបថតរបួសរបស់ជនរងគ្រោះ គឺមិនមែនតែចំពោះថាកើតឡើងនូវអំពើនោះទេ ព្រោះថាតាមសាក្សីថាជនរងគ្រោះមិនមានរបួស ហើយជនរងគ្រោះក៏មិនមានសាក្សីបញ្ជាក់ថាជនរងគ្រោះរងរបួសដែរ ។ យោងតាមមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្នើសុំឲ្យតុលាការឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។ គប្បីតុលាការពិចារណា ។

១៣-សម្តីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំឲ្យតុលាការបន្ធូរបន្ថយទោស ។ គប្បីតុលាការពិចារណា ។

## **សម្រេច**

**១**.ផ្តន្ទាទោសលើឈ្មោះ [redacted] **វិបុល** ភេទប្រុស អាយុ ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ បើកបរឡានដឹកស្រូវ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិពាម [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ស្រេង (រ) ម្តាយឈ្មោះ [redacted] ស៊ីម (រ) ប្រពន្ធឈ្មោះ [redacted] ស្រីវ័ត្ន មានកូន ០២ នាក់ ទោសពីមុន គ្មាន ។

ដាក់ពន្ធនាគាកំណត់រយៈពេល ១(មួយ)ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ១(មួយ)ខែនិង១៦(ដប់ប្រាំមួយ)ថ្ងៃ ឯទោសសល់ពីនោះត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិពាមរាំងលើ ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។

**២**.បង្គាប់ឲ្យឈ្មោះ [redacted] **វិបុល** ដែលមានសាវតាជាតិដូចខាងលើ សងសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន ១.០០០.០០០៛ (មួយលានរៀល) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធឿន សំណើរលើសពីនេះបដិសេធចោល ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា៖ [redacted] | ហត្ថលេខា និងត្រា៖ [redacted] |

---

| | |
|---|---|
| | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| បានឃើញ | ថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ |
| **ចៅក្រមជំនុំជម្រះ** | ធ្វើនៅកណ្តាល ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |

Scanned with CamScanner